**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសុខាភិបាល

លេខ 037 អបស/៩៧

# ប្រកាស

## ស្ដីពី

## ការណែនាំអនុវត្តច្បាប់រំលូតកូន

### ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/១១៩៦/៧២ ចុះថ្ងៃទី ៣០/១១/៩៦ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/០៦ ចុះថ្ងៃទី ២៤/០១/៩៦ ប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញច្បាប់ស្ដីពីការរំលូតកូន ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ជស/រកម/ ១១៩៧/០៦ ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ ចុះថ្ងៃទី ២២ ខែ តុលា ១៩៩៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- យោងតាមការចាំបាច់របស់ក្រសួងសុខាភិបាល

## សំ រេ ច

**ប្រការ ១.-**

ប្រកាសនេះ មានគោលដៅណែនាំ ល័ក្ខខ័ណ្ឌបច្ចេកទេស ដើម្បីអនុវត្តបទបញ្ញត្តិដែលបានចែងក្នុងច្បាប់ស្ដីពីការរំលូតកូន ។

# លក្ខខណ្ឌបច្ចេកទេស

**ប្រការ ២.-**

វេជ្ជបណ្ឌិត ឬ គ្រូពេទ្យមធ្យម ឬ ឆ្មបមធ្យម ដែលអាចធ្វើការរំលូតកូនបាន លុះត្រាតែបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវ ដោយមានលិខិតបញ្ជាក់ពីវគ្គសិក្សារបស់ក្រសួងសុខាភិបាល និងការអនុញ្ញាតិពីក្រសួងសុខាភិបាល ។

ការបណ្តុះបណ្តាលនោះត្រូវធ្វើទៅតាមពិធីសារគ្លីនីករបស់ក្រសួងសុខាភិបាល ដោយផ្តោតលើ :

- បច្ចេកទេសនៃវិធីរំលូតកូន
- ការព្យាបាលបន្ទាន់លើផលវិបាកផ្សេងៗ
- ការពិនិត្យស្ថានភាពសុខភាពស្ត្រីក្នុងការទ្រាំទ្រនឹងការរំលូតកូន
- ការប្រឹក្សាពន្យល់ណែនាំដល់សាមុីខ្លួន ។

**ប្រការ ៣.-**

មុននឹងសំរេចធ្វើការរំលូតកូន អ្នកផ្តល់សេវាត្រូវយកចិត្តទុកដាក់ចំពោះបញ្ហាសុខភាព ដែលចែងក្នុងពិធីសារគ្លីនីក អំពី :

- ការឆ្លងមេរោគធ្ងន់ធ្ងរក្នុងល្អាងត្រគាក
- ជំងឺទឹកនោមផ្អែមធ្ងន់ធ្ងរ
- កំពុងតែមានជំងឺខាន់ស្លឿង
- សុកពាំងមាត់ស្បូន ។

**ប្រការ ៤.-**

ការប្រឹក្សាណែនាំដល់អ្នកត្រូវរំលូតកូន ត្រូវមានខ្លឹមសារដូចខាងក្រោម :

- ពន្យល់អោយបានច្បាស់ពីគុណវិបត្តិនៃការរំលូតកូន

- ផ្តល់ដំបូន្មានអំពីផលប្រយោជន៍នៃសេវាពន្យារកំណើត និងមធ្យោបាយពន្យារកំណើតដែលមាន ព្រមទាំងជួយអោយស្ត្រីបានទទួលមធ្យោបាយពន្យារកំណើតផង ។
- ក្រោយពីធ្វើការរំលូតកូនហើយ ស្ត្រីត្រូវតែដឹងនូវរោគសញ្ញាមួយចំនួនដែលទទួលការថែទាំជាបន្ទាន់ភ្លាមៗ ដូចជា : ក្តៅខ្លួន គ្រុនរងារ ឈឺសាច់ដុំ ឈឺក្នុងពោះ ឬ ឈឺខ្នង តឹងពោះ ធ្លាក់ឈាមច្រើនហើយយូរ ធ្លាក់សធុំក្លិនស្អុយ ការធ្លាក់ឈាមរដូវយូរ (៦សប្តាហ៍ ឬលើសពីនេះ) ក្អួត ឬ ចង្អោរ ។

ប្រការ ៥.-

រៀងរាល់ពេលធ្វើការរំលូតកូន អ្នកដែលត្រូវរំលូតកូន ត្រូវធ្វើកិច្ចសន្យាជាលាយល័ក្ខណ៍អក្សរដោយមានចុះហត្ថលេខា ឬ ស្នាមមេដៃពីសាមុីខ្លួន និងអ្នកពាក់ព័ន្ធតាមករណីនីមួយៗ ដូចបាន រៀបរាប់ក្នុងមាត្រា ៨ នៃច្បាប់ស្តីពីការរំលូតកូន ។

ប្រការ ៦.-

ការរំលូតកូន ត្រូវកំណត់ទៅតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ៨ នៃច្បាប់នេះ ហើយត្រូវអនុវត្តតាមវិធីដូចមានចែងក្នុងពិធីសារគ្លីនីករបស់ក្រសួងសុខាភិបាល ។

## ការធ្វើរបាយការណ៍

ប្រការ ៧.-

ប្រធានអង្គភាពដែលទទួលខុសត្រូវលើការរំលូតកូនទាំងសាធារណៈ និងឯកជន ត្រូវរៀបចំឯកសារច្បាស់លាស់ស្តីពីករណីរំលូតកូននីមួយៗ ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ មកក្រសួងសុខាភិបាល នាយកដ្ឋានមន្ទីរពេទ្យ ដោយឡែងទាត់នូវចំនួនរំលូតគភ៌អាយុតិចជាង ១២សប្តាហ៍ ចំនួន រំលូតគភ៌អាយុច្រើនជាង ១២សប្តាហ៍ មធ្យោបាយរំលូត អាយុនៃអតិថិជននីមួយៗ និងករណីបន្ទាន់ ដែលបានបញ្ជូនទៅមន្ទីរពេទ្យ ព្រមទាំងហេតុផលនៃការបញ្ជូនដោយមិនបញ្ចេញឈ្មោះ អតិថិជន ។

- ផ្ដល់ដំបូន្មានអំពីផលប្រយោជន៍នៃសេវាពន្យារកំណើត និងមធ្យោបាយពន្យារកំណើតដែលមាន ព្រមទាំងជួយអោយស្ត្រីបានទទួលមធ្យោបាយពន្យារកំណើតផង ។

- ក្រោយពីធ្វើការរំលូតកូនហើយ ស្ត្រីត្រូវតែដឹងនូវរោគសញ្ញាមួយចំនួនដែលទទួលការថែទាំជាបន្ទាន់ភ្លាមៗ ដូចជា : ក្ដៅខ្លួន គ្រុនរងារ ឈឺសាច់ដុំ ឈឺក្នុងពោះ ឬ ឈឺខ្នង តឹងពោះ ធ្លាក់ឈាមច្រើនហើយយូរ ធ្លាក់សធុំក្លិនស្អុយ ការធ្លាក់ឈាមរដូវយូរ (៦សប្ដាហ៍ ឬលើសពីនេះ) ក្អួត ឬ ចង្អោរ ។

ប្រការ ៥ .-

រៀងរាល់ពេលធ្វើការរំលូតកូន អ្នកដែលត្រូវរំលូតកូន ត្រូវធ្វើកិច្ចសន្យាជាលាយល័ក្ខណ៍អក្សរ ដោយមានចុះហត្ថលេខា ឬ ស្នាមមេដៃពីសាម៉ីខ្លួន និងអ្នកពាក់ព័ន្ធតាមករណីនីមួយៗ ដូចបាន រៀបរាប់ក្នុងមាត្រា ៨ នៃច្បាប់ស្ដីពីការរំលូតកូន ។

ប្រការ ៦ .-

ការរំលូតកូន ត្រូវកំណត់ទៅតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ៨ នៃច្បាប់នេះ ហើយត្រូវអនុវត្តតាមវិធីដូចមានចែងក្នុងពិធីសារគ្លីនីករបស់ក្រសួងសុខាភិបាល ។

## ការធ្វើរបាយការណ៍

ប្រការ ៧ .-

ប្រធានអង្គភាពដែលទទួលខុសត្រូវលើការរំលូតកូនទាំងសាធារណៈ និងឯកជន ត្រូវរៀបចំឯកសារច្បាស់លាស់ស្ដីពីករណីរំលូតកូននីមួយៗ ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ មកក្រសួងសុខាភិបាល នាយកដ្ឋានមន្ទីរពេទ្យ ដោយទៀងទាត់នូវចំនួនរំលូតគភ៌អាយុតិចជាង ១២សប្ដាហ៍ ចំនួន រំលូតគភ៌អាយុច្រើនជាង ១២សប្ដាហ៍ មធ្យោបាយរំលូត អាយុនៃអតិថិជននីមួយៗ និងករណីបន្ទាន់ ដែលបានបញ្ជូនទៅមន្ទីរពេទ្យ ព្រមទាំងហេតុផលនៃការបញ្ជូនដោយមិនបញ្ចេញឈ្មោះ អតិថិជន ។

ប្រការ ៨.-

នាយកដ្ឋានមន្ទីរពេទ្យនៃអគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល មានភារកិច្ចត្រួតពិនិត្យការរំលូតកូន ទាំងសេវាសាធារណៈ ទាំងសេវាឯកជន ដែលកំពុងធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ការត្រួតពិនិត្យនេះ ត្រូវអនុវត្តដោយផ្អែកតាមល័ក្ខខ័ណ្ឌបច្ចេកទេស ដូចមានចែងក្នុងប្រការ ២ - ៣ - ៤ - ៥ និង ៦ នៃប្រកាសនេះ ។

ប្រការ ៩.-

បទប្បញ្ញត្តិទាំងឡាយណាដែលដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ១០.-

ខុទ្ទកាល័យក្រសួងសុខាភិបាល អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គាធិការដ្ឋាន នាយកដ្ឋានមន្ទីរពេទ្យ និង មន្ទីរសុខាភិបាលខេត្ត-ក្រុង មានភារកិច្ចអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ. ថ្ងៃទី 30 ខែ 04 ឆ្នាំ ២០០២

ឧបនាយករដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រី

អជ្ជ.ហុង_ស៊ុនហួត

ចម្លងជូន :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- អគ្គលេខាធិការដ្ឋាន រាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- សាលាខេត្ត - ក្រុង
- ព្រះរាជកិច្ច
- ឯកសារ-កាលប្បវត្តិ